**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីថ្លែងការព័ត៌មាន
# ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ស៊ីលកេ ស្តូដហ្ស៊ីនស្គី

## បណ្តឹងជាលើកដំបូងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ស្តីពីអំពើហិង្សាលើបញ្ហាយេនឌ័រ នៅក្រោមរបបខ្មែរក្រហម

នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៨ ខាងមុខនេះ ពាក្យបណ្តឹងជាលើកទីមួយស្តីពីឧក្រិដ្ឋកម្មផ្នែកយេនឌ័ររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក នឹងត្រូវប្រគល់ជូនដល់អង្គភាពជនរងគ្រោះរបស់ អ.វ.ត.ក។

ស. គឺជាមនុស្សភេទទីបី (ខ្ទើយ ប្រុសធ្វើស្រី) ម្នាក់ដែលត្រូវបានជាប់ឃុំជាច្រើនលើកច្រើនសារក្នុងកន្លែងកសាងខ្លួនក៏ដូចជាក្នុងគុក ហើយព្រមទាំងត្រូវទទួលរងនូវការរំលោភជាច្រើនដងពីសំណាក់ទាហាននិងកម្មាភិបាលក្នុងរបបខ្មែរក្រហម។ ស.ត្រូវបានដាក់ទណ្ឌកម្មពីបទខុសសីលធម៌និងធ្វើឬកពារជាមនុស្សស្រី។ ស.ត្រូវបានបង្ខំឲ្យកាត់សក់វែងរបស់ខ្លួន និងស្លៀកសំលៀកបំពាក់បុរស (តាមទំលាប់របស់ខ្មែរក្រហម)។ ជាងនេះទៅទៀត ស.ត្រូវខ្មែរក្រហមគំរាមសំលាប់បើសិនណាជារូប ស.បដិសេធមិនព្រមរៀបការជាមួយមនុស្សស្រីហើយព្រមទាំង បានបញ្ជាឲ្យធ្វើការរួមភេទដែលជាផ្នែកមួយនៃកាតព្វកិច្ចអាពាហ៍ពិពាហ៍។ ទង្វើទាំងនេះត្រូវតែដាក់បញ្ចូលទៅក្នុងបទឧក្រិដ្ឋរំលោភផ្លូវភេទ ដោយសារតែពួកគេបានប្រព្រឹត្តឡើងដោយគ្មានការយល់ព្រមស្ម័គ្រចិត្តពីភាគីម្ខាងទៀតនិងធ្វើឡើងក្រោមបញ្ជាប្រកបដោយការគំរាមកំហែងនិងកាលៈទេសៈបង្ខំ។

ឥឡូវនេះ ស. កំពុងស្វែងរកយុត្តិធម៌នៅចំពោះមុខអ.វ.ត.ក ដើម្បីនាំយកមេដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហមឲ្យមកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលស.បានរង។

នេះគឺជាពាក្យបណ្តឹងលើកដំបូងចំពោះអ.វ.ត.កទាក់ទងនឹងបទល្មើសហិង្សាផ្លូវភេទនៅក្រោមរបបខ្មែរក្រហម។ ចាប់ពីពេលនេះតទៅឧក្រិដ្ឋកម្មហិង្សាលើផ្លូវភេទដែលលាក់ទុកកំបាំងជាយូរណាស់

មកហើយនឹងត្រូវរើកកាយឡើង។ យោងតាមការយល់ឃើញជាទូទៅ អំពើហិង្សាលើផ្លូវភេទបានកើតឡើងក្នុងរបបខ្មែរក្រហមប៉ុន្តែមិនត្រូវបានចងក្រងជាផ្លូវការដូចជាអំពើសាហាវឃោរឃៅដ៏ទៃទៀតនោះទេ។

ការខកខានមិនបានដាក់ទោសទៅលើជនល្មើសគឺច្បាស់ណាស់ថាកំពុងនាំឲ្យឈានទៅកាន់វប្បធម៌និទណ្ឌភាពសំរាប់បទឧក្រិដ្ឋប្រភេទនេះ។ បណ្តាមេដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហមត្រូវទទួលខុសត្រូវលើអំពើហិង្សាផ្លូវភេទទាំងអស់ដែលបានប្រព្រឹត្តដោយទាហាននិងកម្មាភិបាលរបស់ពួកគេព្រោះថាបទឧក្រិដ្ឋទាំងនោះត្រូវបានប្រព្រឹត្តឡើងតាមគោលនយោបាយទូទៅទាក់ទងនឹងឥរិយាបថផ្លូវភេទដែលបានព្យាករណ៍ទុកជាមុនរួចហើយនូវផលវិបាកនានា។ ដោយសារតែការគ្រប់គ្រងគ្មានប្រសិទ្ធិភាពទៅលើអ្នកនៅក្រមបង្គាប់របស់ខ្លួន បណ្តាអ្នកដឹកនាំជាន់ខ្ពស់ទាំងនោះត្រូវទទួលខុសត្រូវចំពោះបទល្មើសហិង្សាផ្លូវភេទទាំងនោះ។

មកទល់ពេលនេះ ការស៊ើបអង្កេតរបស់អ.វ.ត.ក មិនបានបញ្ចូលបទល្មើសហិង្សាផ្លូវភេទនោះទេដោយយោងលើមូលហេតុខ្វះភស្តុតាងគ្រប់គ្រាន់។ ការស៊ើបអង្កេតទៅលើបញ្ហាទាំងនេះមិនដែលត្រូវបានរៀបចំឡើងនោះទេ។

ដូច្នេះហើយ បណ្តឹងដែលបានរៀបរាប់ខាងលើនេះ ស្នើសុំឲ្យមានការបើកការស៊ើបអង្កេតបន្ថែមទៀតទៅលើអំពើហិង្សាយេនឌ័រ។ នេះគឺជាជំហានមួយដើម្បីលើកទឹកចិត្តដល់បណ្តាជនរងគ្រោះដែលទទួលរងឧក្រិដ្ឋកម្មបែបនេះដ៏ទៃទៀតមកធ្វើការទាមទារឲ្យមានការទទួលស្គាល់និងយុត្តិធម៌ចំពោះការឈឺចាប់ដែលមិនមានការយកចិត្តទុកដាក់ជាច្រើនទេរហូតមកដល់សព្វថ្ងៃនេះ។

បណ្តាជនរងគ្រោះដែលចាប់អារម្មណ៍ អាចទទួលព័ត៌មានបន្ថែមពីអង្គភាពជនរងគ្រោះរបស់អ.វ.ត.ក ក៏ដូចជាពីបណ្តាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកផ្សេងៗទៀត។ លើសពីនេះទៅទៀតដើមបណ្តឹងទាំងឡាយអាចនឹងទទួលបាននូវវិធានការការពារមួយចំនួនដើម្បីបង្កឱកាសសមរម្យដល់ពួកគេក្នុងការនិយាយនិងទំលាយនូវអ្វីដែលបានលាក់កប់ជាយូរមកហើយនោះ។

---

សេចក្ដីដូចបានរៀបរាប់ខាងលើនេះ យើងខ្ញុំសូមគោរពអញ្ជើញបណ្ដាអ្នកសារព័ត៌មាននិងបណ្ដាអ្នកចាប់អារម្មណ៍ទាំងឡាយ ចូលរួមក្នុងសន្និសីទសារព័ត៌មានមួយ ដែលនឹងប្រព្រឹត្តធ្វើឡើង

**នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៨ វេលាម៉ោងង ០២៖៣០ រសៀល**

នៅសណ្ឋាគាសាន់វ៉េ (Sunway) ដែលមានអសយដ្ឋានផ្ទះលេខ ១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ក្រុងភ្នំពេញ។

**សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង**

លោកស្រីសហាមេធាវី ស៊ីលកេ ស្ទូដហ្សីនស្គី  ទូរស័ព្ទលេខ ០១២៦៥៧០១៤
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មានរបស់អ.វ.ត.ក លោករាជ សម្បត្តិ  ទូរស័ព្ទលេខ ០១២៤៨៨១៥៦
ប្រធានផ្នែកកិច្ចការសារធារណៈរបស់អ.វ.ត.ក បណ្ឌិត ហេឡិន ចារវីស
ទូរស័ព្ទលេខ ០១២ ៤៨៨ ១៣៤

**អង្គការគាំទ្រ**

- Medica Mondial
- បណ្ដាញបុរសស្ត្រីដើម្បីអភិវឌ្ឍ
- បណ្ដាញស្ត្រីរួមរួម
- អង្គការស្ត្រីដើម្បីការផ្លាស់ប្ដូរ
- បណ្ដាញអ្នករកស៊ីផ្លូវភេទអាស៊ីប៉ាស៊ីហ្វិក